# របាយការណ៍ប្រចាំត្រីមាសទីមួយ ឆ្នាំ ២០២១

០១ មករា - ៣១ មីនា ២០២១

## អ រិម អេ (ខេមបូឌា) ម.ក

RMA (CAMBODIA) PLC.



## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទី១ ២០២១ | ២០២០ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤២៨.៣២៦.៧២៩ | ៤១៨.៩២៩.៥៧៧ |
| បំណុលសរុប | ១៩៧.១៨៦.១៩៨ | ២២៩.២២១.៥២០ |
| មូលធនក្រុមហ៊ុនសរុប | ២៣១.១៤០.៥៣១ | ១៨៩.៧០៨.០៥៧ |
| **ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល)** | **ត្រីមាសទី១ ២០២១** | **ត្រីមាសទី១ ២០២០** |
| ចំណូលសរុប | ៤៨១.៦៥៥.០០៨ | ៤២៣.០៩៦.៨២២ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ៥៩.៨៣៥.៨៤៧ | ៥១.៩៣៦.០៣៩ |
| ប្រាក់ចំណេញ/(ខាត)ក្រោយបង់ពន្ធ | ៤៩.២៨៧.៩៧៤ | ៣៩.៦៤៨.៨១៦ |
| ចំណូលផ្សេងៗសង្ខេបសរុប (Total Comprehensive Income) | ៤៩.១១៧.៩៧៤ | ៣៩.៥៤៧.៤២៩ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី១ ២០២១** | **២០២០** |
| អនុបាតសាធនភាព | ០,៨៥ | ១,២១ |
| អនុបាតចរន្ត (Current Ratio) | ៣,១០ | ២,៣៤ |
| អនុបាតចរន្តលឿន (Quick Ratio) | ២,០៩ | ១,៣២ |
| **អនុបាតចំណេញភាព** | **ត្រីមាសទី ១ ២០២១** | **ត្រីមាសទី ១ ២០២០** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ១១,៦% | ៨,៦% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ២៣,៣% | ២៥,៥% |

| | | |
|---|---|---|
| គម្លាតចំណេញដុល (Gross Profit Margin) | ១៥,៣% | ១៦,៥% |
| គម្លាតចំណេញ (Profit Margin) | ១០,២% | ៩,៤% |
| អនុបាតលទ្ធភាពសងការប្រាក់<br><br>(Interest Coverage Ratio) | ២៦,១៣ | ១៣,៩១ |

## ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប




### មូលធនសរុប (គិតជាពាន់រៀល)

ត្រីមាសទី១ ឆ្នាំ២០២១
២៣១.១៤០.៥៣១

ឆ្នាំ២០២០
១៨៩.៧០៨.០៥៧

### ផលលើមូលធនជាមធ្យម

ត្រីមាសទី១ ឆ្នាំ២០២១
២៣,៣%

ត្រីមាសទី១ ឆ្នាំ២០២០
២៥,៥%

## ប្រាក់ចំណូល និងចំណូលសុទ្ធ (គិតជាពាន់រៀល)



## សមាជិកក្រុមប្រឹក្សាភិបាល



លោក Chris Manley | លោក ឯន សាំង | លោក Kevin Wលោក | លោក Tom Whitcraft | លោក Ith Vichit

លោក Kevin Whitcraft

ប្រធានក្រុមប្រឹក្សាភិបាល

លោក ឯន សាំង

អភិបាលប្រតិបត្តិ

លោក Tom Whitcraft

អភិបាលមិនប្រតិបត្តិ

លោក Chris Manley

អភិបាលមិនប្រតិបត្តិ

លោក Ith Vichit

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ **ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក** (តទៅនេះហៅកាត់ថា "**ក្រុមហ៊ុន RMAC**") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា។

ក្នុងអំឡុងត្រីមាសទី ១ ឆ្នាំ ២០២១ ប្រទេសកម្ពុជាបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការផ្ទុះឡើងនៃករណីជម្ងឺកូវីដ-១៩។ ចាប់តាំងពីពាក់កណ្តាលខែកុម្ភៈ ប្រទេសកម្ពុជាបានរកឃើញថាមានករណីកើនឡើងរហូតដល់ ២១.០០០ នាក់ឯណោះ។ ប្រជាពលរដ្ឋត្រូវបានអាជ្ញាធរស្នើសុំឲ្យបញ្ឈប់ការធ្វើដំណើរពីខេត្តមួយទៅខេត្តមួយផ្សេងទៀត ផ្សារទំនើប ភោជនីយដ្ឋាន និងទីកន្លែងប្រជុំជនជាច្រើនត្រូវបានបិទ ហើយអាជីវកម្មទាំងអស់បានធ្លាក់ចុះយ៉ាងខ្លាំង។

ក្នុងអំឡុងត្រីមាសទី ១ អាជីវកម្មរបស់ក្រុមហ៊ុន RMAC បានរងផលប៉ះពាល់តិចតួចប៉ុណ្ណោះ។ ការលក់មានការកើនឡើង +១៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនដែលបង្ហាញពីភាពខ្លាំងក្លានៃតម្រូវការលើផលិតផលសំខាន់ៗរបស់យើងជាពិសេស យានយន្តម៉ាក Ford និងគ្រឿងចក្រកសិកម្មពីម៉ាក John Deere ។

ក្រុមហ៊ុនបានបន្តបើកសម្ពោធនូវផលិតផលដែលត្រូវនឹងតម្រូវការរបស់អតិថិជនកម្ពុជាដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើបច្ចេកវិទ្យា ការប្រើប្រាស់ប្រេងតិច និង សុវត្ថិភាពរបស់អតិថិជនចំពោះផលិតផលដែលយើងបានលក់។ ឧទាហរណ៍ដ៏សំខាន់នៃការបង្ហាញនេះគឺការសម្ពោធរថយន្តម៉ាក All-New Ford Territory នៅខែមករា ឆ្នាំ២០២១ ដែលជាទំព័រថ្មីមួយនៃរថយន្តប្រភេទ SUV មានទំហំមធ្យម។

ក្រុមហ៊ុន RMAC នឹងបន្តអនុវត្តយុទ្ធសាស្រ្តអាជីវកម្មជាក្រុមហ៊ុនផ្គត់ផ្គង់និងថែទាំ ឈានមុខគេផ្នែកយានយន្ត គ្រឿងបរិក្ខារកសិកម្ម សំណង់ និងគ្រឿងបរិក្ខារជំនួយ (materials handling equipment) ដែលមានស្តង់ដារលំដាប់ពិភពលោកនៅប្រទេសកម្ពុជា។

ក្រុមហ៊ុន RMAC បានផ្តោតសំខាន់ និងយកចិត្តទុកដាក់ជាបន្តបន្ទាប់ក្នុងនាមជាក្រុមហ៊ុនមួយដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជាលើការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពគ្រប់គ្រង និងការឆ្ពោះទៅមុខក្នុងរយៈពេលវែងរបស់ក្រុមហ៊ុន ក្នុងខណៈដែលក្រុមហ៊ុនក៏យល់ច្បាស់ពីទំនួលខុសត្រូវលើតួនាទី សង្គម និងបរិស្ថានផងដែរ។ ដូចជាឧទាហរណ៍នៃការតភ្ជាប់ និងចែករំលែកបន្តដល់សហគមន៍ ក្នុងខែកុម្ភៈ ឆ្នាំ២០២១ ដែលក្រុមហ៊ុន បានប្រគល់រថយន្តចំនួន ២ គ្រឿងដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកវិទ្យានៃរថយន្ត Ford នៃវិទ្យាស្ថានពហុបច្ចេកទេសជាតិកម្ពុជា។

ក្រុមហ៊ុននឹងនៅតែបន្តនាំយកនូវផលិតផលថ្មីៗនិងសកម្មភាពផ្សេងទៀតសម្រាប់ត្រីមាសខាងមុខ។

ខ្ញុំបាទតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមថ្លែងអំណរគុណដល់អតិថិជនដែលមានភក្តីភាពដែលបានគាំទ្រដល់ក្រុមហ៊ុនយើងក្នុងគ្រាលំបាកក្នុងព្រះរាជាណាចក្រកម្ពុជានេះ។ ហើយយើងក៏សូមជូនពរឲ្យប្រជាជនកម្ពុជាទាំងអស់មានសុវត្ថិភាព និងសុខភាពល្អគ្រប់ៗគ្នា និងចៀសផុតពីជម្ងឺ កូវីដ-១៩ ផងដែរ។

R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល
ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១

## មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....................................................................................3

ក្រាបស៊្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ....................................................................................5

សមាជិកក្រុមប្រឹក្សាភិបាល ....................................................................................7

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ....................................................................................8

ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ .................................................................................... 11

ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ .................................................................................... 11

ខ. សកម្មភាពអាជីវកម្ម .................................................................................... 11

គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស .................................................................................... 12

ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច .................................................................................... 15

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក .................................................................................... 15

ខ. រចនាសម្ព័ន្ធប្រាក់ចំណូល .................................................................................... 16

ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ .................................................................................... 17

ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង .................................................................................... 18

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ .................................................................................... 18

ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ .................................................................................... 20

គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល .................................................................................... 20

ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ .................................................................................... 21

ង. ផលប៉ះពាល់នៃអតិផរណា .................................................................................... 21

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល .................................................................................... 21

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ .................................................................................... 22

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| | |
|---|---|
| **ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ** | អ អិម អេ (ខេមបូឌា) ម.ក |
| **ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង** | RMA (CAMBODIA) PLC |
| **លេខកូដស្តង់ដារ** | KH2000121A44 |
| **អាសយដ្ឋាន** | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| **លេខទូរស័ព្ទ** | +៨៥៥ (០) ២៣ ៨៨៣ ៥៨៨ / ១២ ៨៦៧ ៦៩៧ |
| **លេខទូរសារ** | +៨៥៥ (០) ២៣ ៥២៦ ៧៥២ |
| **គេហទំព័រ** | www.cambodia.rmagroup.net |
| **អ៊ីម៉ែល** | saing.ngorn@rmagroup.net |
| **លេខចុះបញ្ជីក្រុមហ៊ុន** | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| **លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន** | ០០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| **ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ** | លោក ងន សាំង |
| **លេខាធិការក្រុមហ៊ុន** | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Jaguar Land Rover, John Deere, TCM, JCB, FUSO, និង Piaggio។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងការតម្លើងជំបូងគេបង្អស់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

### ខែមករា ឆ្នាំ២០២១

#### ការបើកសម្ពោធផលិតផលថ្មី

ភ្នំពេញ, ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១ - ក្រុមហ៊ុន អ អិម អេ ខេមបូឌា ដែលជាអ្នកចែកចាយផ្លូវការសម្រាប់ក្រុមហ៊ុន Ford នៅកម្ពុជាបានសម្ពោធរថយន្តម៉ាក ALL-NEW FORD TERRITORY នៅ The Premier Centre ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ដែលមានភ្ញៀវជាសរុបចំនួន ២.៧០០ នាក់បានចូលរួមក្នុងពិធីបើកសម្ពោធនេះ ដោយបានចែកចេញជាពីរថ្ងៃដើម្បីអនុវត្តតាមយុទ្ធសាស្ត្រ ការរក្សាគម្លាតនៃជម្ងឺកូវីដ-១៩ផងដែរ។ ការបើកបរសាកល្បងត្រូវបានធ្វើឡើង ដោយមានអ្នកបើកបរចំនួនជាង ២០០ នាក់។ អ្នកបើកបរទាំងអស់សុទ្ធតែទទួលបាននូវការណែនាំ និងហ្វឹកហាត់ពីគ្រូបើកបរយ៉ាងមានជំនាញ។ ក្រុមហ៊ុន អ អិម អេ ខេមបូឌាបានទទួលជោគជ័យយ៉ាងខ្លាំងជាមួយការបើកសាកល្បងនេះ។ វាបាននាំមកនូវរថយន្ត All-New Territory ជាមួយនឹងភាពងាយស្រួលចំពោះអ្នកបើកបរ និងអ្នកដែលជាម្ចាស់ដំបូងគេក៏ដូចជាអតិថិជនដែលមានភក្ដីភាព និងការរំពឹងទុកជាដើម។

រថយន្ត ALL-NEW FORD TERRITORY







### ខែកុម្ភៈ ឆ្នាំ២០២១

#### ក្រុមហ៊ុន ហ្វដខេមបូឌា ប្រគល់យានយន្តទៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលបច្ចេកទេសរថយន្ត Ford និងវិទ្យាស្ថាន NPIC

ភ្នំពេញថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមហ៊ុនហ្វដខេមបូឌាបានចូលរួមក្នុងពិធីប្រគល់រថយន្ត Ford Ranger Wildtrak ចំនួន ២ គ្រឿងដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសរថយន្តFordនៅវិទ្យាស្ថានពហុបច្ចេកវិទ្យាជាតិកម្ពុជា (NPIC)។ ព្រឹត្តិការណ៍នេះមានការចូលរួមពីភ្ញៀវជាង ៧០០ នាក់រួមមានបុគ្គលិកក្រុមហ៊ុន អ អិម អេ បុគ្គលិក NPIC និស្សិត NPIC មន្ត្រីរដ្ឋាភិបាល និងអ្នកសារព័ត៌មានផងដែរ។ លោក ងន សាំង នាយកប្រតិបត្តិក្រុមហ៊ុន អ អិមអេ ខេមបូឌា ឯកឧត្តម ប៊ុន ភារិន នាយកវិទ្យាស្ថាន NPIC និង ឯកឧត្តម Pok Pan រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើសេចក្តីថ្លែងទៅកាន់អ្នកចូលរួម។ ប្រតិភូបានទៅមើលទីតាំងនានានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសរថយន្ត Ford ហើយអ្នកជំនាញបច្ចេកទេសរបស់យើងបានបង្ហាញជូនពួកគេនូវមុខងារនៃកន្លែងនីមួយៗ។







## ខែកុម្ភៈ ឆ្នាំ២០២១

### ដំណើរកំសាន្តគ្រួសារ Ford EcoSport

ភ្នំពេញថ្ងៃទី ២៧ ខែមករាឆ្នាំ ២០២១ - ដំណើរកម្សាន្តគ្រួសារ Ford EcoSport បានវិលត្រឡប់មកនៅឆ្នាំ ២០២១ ហើយ! ក្រុមហ៊ុន ហ្វដ ខេមបូឌា កំពុងរៀបចំការធ្វើដំណើរជាលក្ខណៈគ្រួសារសម្រាប់តែអតិថិជន Ford EcoSport ប៉ុណ្ណោះ។ ព្រឹត្តិការណ៍រយៈពេល ៣ ថ្ងៃនឹងត្រូវរៀបចំឡើងចាប់ពីថ្ងៃទី ៥-៧ ខែកុម្ភៈ ការធ្វើដំណើរចាកចេញពីរាជធានីភ្នំពេញនឹងនាំពួកគេឆ្លងកាត់ទៅខេត្តសៀមរាប។ គោលបំណងនៃព្រឹត្តិការណ៍នេះគឺដើម្បីបង្កើតបុគ្គលិកលក្ខណៈឃីហោ Ford EcoSport និងគុណតម្លៃរបស់វាដូចជាការសប្បាយរីករាយ អារម្មណ៍ល្អ ការបើកបរប្រចាំថ្ងៃដោយមិនមានការព្រួយបារម្ភ និងទុកឲ្យ



អតិថិជនក្លាយជាផ្នែកមួយនៃបទពិសោធន៍។ សូមឲ្យដំណើរផ្សងព្រេងចាប់ផ្តើម។



## ខែមីនា ឆ្នាំ២០២១

### ទិវានារីអន្តរជាតិ

ទិវាសិទ្ធិនារីអន្តរជាតិប្រារព្ធធ្វើឡើងក្នុងខែមិនាដើម្បីអបអរសាទរសមិទ្ធិផលរបស់ស្ត្រីទៅលើផ្នែកវប្បធម៌ ដែលនាំមកនូវការយកចិត្តទុកដាក់លើសិទ្ធិស្ត្រី សមភាពយេនឌ័រ និង អំពើហឹង្សាជាថ្មីម្តងទៀត ចំពោះស្ត្រី។ ប្រធានបទយុទ្ធនាការនៅឆ្នាំនេះគឺ #Choose To Challenge ដើម្បីស្វែងរក និងអបអរសាទរសមិទ្ធិផលរបស់ស្ត្រី និងជួយបង្កើតពិភពលោកមានការចូលរួម។




### ក្រុមហ៊ុន អ អិម អេ ខេមបូឌា ផ្តល់អំណោយដល់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

នៅថ្ងៃទី ៥ ខែមីនា ឆ្នាំ២០២១ ក្រុមហ៊ុន អ អិម អេខេមបូឌា បានផ្តល់ម៉ាសការពារចំនួន ៥ ម៉ឺនម៉ាស ទឹកលាងសម្អាតដៃចំនួន ២៤០ ដប, ដែលអនាម័យសម្អាតដៃ ១០០ មីលីលីត្រចំនួន ២,១០០ ដប និងដែលអនាម័យសម្អាតដៃ ៥០០ មីលីលីត្រ ៥០៤ ដបដល់អគ្គនាយកដ្ឋានគយនិងរដ្ឋាករដើម្បីជួយប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ-១៩។





## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

សមិទ្ធិផលសំខាន់ៗក្នុងត្រីមាសទី១ នៃឆ្នាំ២០២១ រួមមាន៖

**ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖**

សម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ រថយន្តម៉ាក Ford បានបង្កើនឥទ្ធិពលរបស់ខ្លួននៅលើទីផ្សារ ដែលកាន់កាប់ចំណែកទីផ្សារភាគហ៊ុនចំនួន ៤២,១៧% សម្រាប់យានយន្តថ្មីក្នុងអំឡុងពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២១ បើប្រៀបធៀបទៅនឹង ៣៦,៥% ក្នុងឆ្នាំ២០២០។ រថយន្តម៉ាក Ford Ranger នៅតែបន្តជារថយន្តដែលលក់ដាច់ជាងគេក្នុងចំណោមទីផ្សាររថយន្តក្នុងប្រទេសកម្ពុជា។

**គ្រឿងចក្រម៉ាក John Deere៖** នៅជាអ្នកនាំមុខទី២នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា។

**លទ្ធផលហិរញ្ញវត្ថុ៖**

ក្រុមហ៊ុន RMAC ទទួលបានចំណូលចំនួន ៤៨១,៧ ប៊ីលានរៀល ក្នុងដំណាច់ត្រីមាសទី១ នៃឆ្នាំ២០២១ ដែលមានការកើនឡើងចំនួន +១៣,៨% ធៀបនឹងដំណាច់ត្រីមាសទី៤១ នៃឆ្នាំ២០២០។ សម្រាប់ដំណាច់ត្រីមាសទី១ នៃឆ្នាំ២០២១ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ៤៩,៣ ប៊ីលានរៀល ដែលកើនឡើងចំនួន +២៤,៣% ធៀបនឹងដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០១៩ ដោយសារតែ៖

- ប្រាក់ចំណេញដុលចំនួន ៣,៦ ប៊ីលានរៀល ក្នុងដំណាច់ត្រីមាសទី១ នៃឆ្នាំ២០២០ បានមកពីកំណើនលក់នៅដំណាច់ត្រីមាសទី១ នៃឆ្នាំ២០២១ (ការលក់កើនឡើងចំនួន +៥៨,៦ ប៊ីលានរៀលបើប្រៀបធៀបទៅនឹងឆ្នាំមុន)។
- ប្រាក់ចំណាយបានធ្លាក់ចុះចំនួន ១,៧ ប៊ីលានរៀល លើការចំណាយហិរញ្ញវត្ថុក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដែលប្រៀបធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២០។
- ប្រាក់ចំណាយបានធ្លាក់ចុះចំនួន ២,៣ ប៊ីលានរៀល លើការចំណាយសម្រាប់ការប្រតិបត្តិការជំនួញដែលបណ្តាលមកពីការចំណាយលើទីផ្សារតិច ហើយទទួលបានការចំណេញច្រើនជាងពីអត្រាប្តូរប្រាក់ក្នុងត្រីមាសទី១ ឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ២០២០។

ហើយពត៌មានហិរញ្ញវត្ថុ (មិនទាន់ធ្វើសវនកម្ម) សំខាន់ៗសម្រាប់ដំណាច់ត្រីមាសនោះគឺ៖

- ទ្រព្យសកម្មសរុបរក្សានៅចំនួន ៤២៨ ប៊ីលានរៀល ដែលបានកើនឡើងចំនួន ៩,៤ ប៊ីលានរៀល តាមរយៈការកាត់បន្ថយសារពើភណ្ឌ (ពីចំនួន ១៥៣ ប៊ីលានរៀលបើធៀបនឹងចុងឆ្នាំ២០២០ ទៅ ១២០,៧ ប៊ីលានរៀលនៅចុងខែមិនា ឆ្នាំ២០២១) និងចំនួនទឹកប្រាក់ ៧,១ ប៊ីលានរៀលនៃការធ្លាក់ចុះនៃការបង់ពន្ធទ្រព្យសម្បត្តិ។
- ចំនួនទឹកប្រាក់ ៤៦,៧ ប៊ីលានរៀលនៃទំហំសាច់ប្រាក់ (cash position) របស់ក្រុមហ៊ុន ត្រូវបានពង្រឹងដោយបានបង្កើនឡើងដល់ចំនួន ២០៥,៨ ប៊ីលានរៀល។

- ការកើនឡើងនូវទឹកប្រាក់ចំនួន ២ ប៊ីលានរៀលបានមកពីការធ្វើពាណិជ្ជកម្ម និងចំណូលផ្សេងៗទៀត។
- មូលធនរបស់ម្ចាស់ភាគហ៊ុនមានត្រឹមចំនួន ២៣១,១ ប៊ីលានរៀល ដែលបានកើនឡើងចំនួន ៩១,៤ ប៊ីលានរៀល ធៀបនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។
- លទ្ធផលនៃលំហូរសាច់ប្រាក់សុទ្ធពីប្រតិបត្តិការសម្រាប់ត្រីមាសទី១ នៃឆ្នាំ២០២១ មានភាពរឹងមាំដែលមានចំនួន ៣៩,៦ ប៊ីលានរៀល ដែលបានកើនឡើងចំនួន ៧៩ ប៊ីលានរៀល ធៀបនឹង ឆ្នាំ ២០២០។

ក្រុមហ៊ុន RMAC នៅតែបន្តធ្វើការវិនិយោគនូវសាច់ប្រាក់ចំនួន ៤,២ ប៊ីលានរៀល ក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដោយរាប់បញ្ចូលទាំងរថយន្តម៉ាកថ្មី សម្រាប់ប្រតិបត្តិការនិងឧបករណ៍ប្រតិបត្តិការបន្ថែម។

## ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Jaguar Land Rover, Fuso, John Deere និង JCB។ ក្នុងអំឡុងពេលដែលវិស័យអាជីវកម្មផ្សេងៗកំពុងតែអភិវឌ្ឍខ្លួន អាជីវកម្ម Ford ក៏បានដើរតួរជាវិស័យចម្បងមួយនៃរចនាសម្ព័ន្ធប្រាក់ចំណូលរបស់ក្រុមហ៊ុននាពេលបច្ចុប្បន្ននេះផងដែរ។ អាជីវកម្ម Ford ដែលរួមមានការលក់យានយន្ត សេវាកម្មក្រោយការលក់ និងការលក់គ្រឿងបន្លាស់ ដែលបានផ្តល់ចំណូលជាង ៨៧,៧% នៃប្រាក់ចំណូលសម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ (បើធៀបនឹង ៨៩,៩% នៃប្រាក់ចំណូលសម្រាប់ត្រីមាសទី១ ឆ្នាំ២០២០)។

ចំណូលទទួលបានតាមផ្នែក ត្រូវបានបង្ហាញក្នុងផ្នែកទី៤ នៃរបាយការណ៍នេះ។

## ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅកាន់ឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នប្រចាំត្រីមាស គិតត្រឹម

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៨៨១,៧ ប៊ីលានរៀល ត្រូវបានកើនឡើងចំនួន +៥៨,៦ ប៊ីលានរៀល ឬ +១៣,៩ ភាគរយ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០។

#### ២. ផ្នែកនៃចំណូល

| គិតពាន់រៀល | ត្រីមាសទី១ ឆ្នាំ ២០២១ | ភាគរយនៃភាគហ៊ុន | ត្រីមាសទី១ ឆ្នាំ ២០២០ | ភាគរយនៃភាគហ៊ុន |
|---|---|---|---|---|
| Ford | ៨២២.៨៩១.១៨៦ | ៨៧,៧% | ៣៨០.២៧០.៨៨៣ | ៨៩,៩% |
| ប្រតិបត្តិការផ្សេងទៀត | ៦៥.៨៨៨.១២៣ | ១៣,៧% | ៨៧.៦១៧.៨៣៥ | ១១,៣% |
| ការលុបបំបាត់សាជីវកម្ម (Corporate Elimination) | (៦.៧២៨.២៦១) | -១,៤% | (៨.៧៩០.៩៧៥) | -១,១% |
| សរុប | ៨៨១.៦៥៥.០០៨ | ១០០,០% | ៨២៣.០៩៦.៩០៣ | ១០០,០% |

ចំណូលរបស់ Ford បានកើនឡើងចំនួន ៨២,២ ប៊ីលានរៀល (ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន +១១,១%) ដែលជាលទ្ធផលនៃការលក់ដ៏ខ្ពស់។ ចំណូលនៃប្រតិបត្តិការផ្សេងទៀតត្រូវបានកើនឡើងចំនួន ១៨,៣ ប៊ីលានរៀល (កើនឡើងចំនួន +៣៨,៤% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០) ជាមួយនឹងបរិមាណខ្ពស់សម្រាប់ម៉ាក JOHN DEERE JLR និង FUSO។

#### ៣. គម្លាតចំណេញដុល

| គិតជាពាន់រៀល | ត្រីមាសទី៤ ឆ្នាំ ២០២០ | ត្រីមាសទី៤ ឆ្នាំ ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៨៨១.៧៣៨.១១៧ | ៨២៣.០៩៦.៨២២ | ៥៨.៦៣៧.២៩៥ | ១៣,៩% |
| ចំណេញដុល | ៧៣.៥៥៤.៥១៨ | ៦៩.៩៩០.៨៨៥ | ៣.៥៦៤.០៣៣ | ៥,១% |
| គម្លាតចំណេញដុល | ១៥,៣% | ១៦,៥% | | |

គម្លាតចំណេញដុលនៃត្រីមាសទី១ ឆ្នាំ២០២១ បានថយចុះចំនួន ១៥,៣% (ធៀបនឹង ១៦,៥% នៃត្រីមាសទី១ ឆ្នាំ២០២០) ដោយសារការប្រកួតប្រជែងក្នុងនៅអំឡុងពេលកូវីត-១៩។ ទោះបីជាយ៉ាងណាក្តី ប្រាក់ចំណូលសរុបប្រចាំត្រីមាសទី១ ឆ្នាំ២០២១ បានកើនឡើងចំនួន ១៣,៨% បើធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២០។

## ៤. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី១ ឆ្នាំ ២០២១ | ត្រីមាសទី១ ឆ្នាំ ២០២០ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៤៨១.៧៣៤.១១៧ | ៤២៣.០៩៦.៨២២ | ៥៨.៦៣៧.២៩៥ | ២០,៧% |
| ចំណេញដុល | ៧៣.៥៥៤.៥១៨ | ៦៩.៩៩០.៤៨៥ | ៣.៥៦៤.០៣៣ | ៥,១% |
| គម្លាតចំណេញដុល | ១៥,៣% | ១៦,៥% | | |
| ចំណាយ | ១១.៧៤៣.៨៤០ | ១៤.០២៩.៩៩១ | (២.២៨៦.១៥១) | -១៦.៣% |
| ចំណាយហិរញ្ញវត្ថុ | ២.៣៦៥.០៦៨ | ៤.០២៤.៤៥៥ | (១.៦៥៩.៣៨៧) | -៤១,២% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ៥៩.៤៤៥.៦១០ | ៥១.៩៣៦.០៣៩ | ៧.៥០៩.៥៧១ | ១៤,៥% |
| គម្លាត | ១២,៣% | ១២,៣% | | |

គម្លាតប្រាក់ចំណេញមុនបង់ពន្ធ សម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ មានចំនួន ១២,៣% ត្រូវបានផ្តល់ឲ្យដោយ ១២,៣% ក្នុងត្រីមាសទី១ ឆ្នាំ២០២០។ ការធ្លាក់ចុះនៃប្រាក់ចំណេញដុលពី ១៦,៥% នៅក្នុងត្រីមាសទី១ ឆ្នាំ២០២០ ទៅ ១៥,៣% នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ត្រូវបានទូទាត់សងដោយការថយចុះនូវចំណាយ និងចំណាយហិរញ្ញវត្ថុក្នុងពេលដំណាលគ្នាដែលទទួលបានប្រាក់ចំណេញដូចគ្នាមុនពេលកំណត់ពន្ធ។

## ៥. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី១ ឆ្នាំ ២០២១ | ត្រីមាសទី១ ឆ្នាំ ២០២០ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៥៩.៤៤៥.៦១០ | ៥១.៩៣៦.០៣៩ | ៧.៥០៩.៥៧១ | **១៤,៥%** |
| ចំណាយពន្ធ | ១០.១៤៩.៥៤០ | ១២.២៨៧.២២៣ | (២.១៣៧.៦៨៣) | **-១៧,៤%** |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ៤៩.២៩៦.០៧០ | ៣៩.៦៤៨.៨១៦ | ៩.៦៤៧.២៥៤ | **២៤,៣%** |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | **១០,២%** | **៩.៤%** | | |

គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ សម្រាប់ត្រីមាសទី១ ឆ្នាំ ២០២១ មានចំនួន ១០,២% កើនឡើងពីចំនួន ៩,៤% ក្នុងត្រីមាសទី១ ឆ្នាំ ២០២០ ដែលបណ្តាលមកពីការលើកទឹកចិត្តលើថ្លៃពន្ធលើការចេញប័ណ្ណបំណុល

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ការរាតត្បាតនូវវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាបានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងទាំងតម្រូវការ និងការផ្គត់ផ្គង់ ជាពិសេសតាំងពីត្រីមាសទី២ ឆ្នាំ២០២០។ ការផ្គត់ផ្គង់ទទួលតម្រូវផលប៉ះពាល់ខ្លាំងដោយការដាក់បម្រាមគោចរ (Lock Down) ជាពិសេសរោងចក្ររថយន្ត Ford នៅប្រទេសថៃ ប៉ុន្តែស្ថានភាពបានប្រសើរឡើងវិញចាប់តាំងពី ត្រីមាសទី៣ ឆ្នាំ ២០២០។

តម្រូវការទីផ្សារត្រូវបានប៉ះពាល់តាមរយៈការពន្យារពេល និងការលុបចោលនូវគម្រោងឯកជន និងគម្រោងសាធារណៈធំៗ ការធ្លាក់ចុះនូវជំនឿទុកចិត្តរបស់អតិថិជន ការខាតបង់របស់អាជីវកម្មទេសចរណ៍ បដិសណ្ឋាកិច្ច និង ភាពតឹងរឹងជាងមុនចំពោះកម្ចីធនាគារ។ នៅដំណាច់ត្រីមាសទី១ ឆ្នាំ២០២១ សេវាកម្មទេសចរណ៍និងបដិសណ្ឋារកិច្ចបានទទួលរងផលប៉ះពាល់ជាខ្លាំងដោយសារជម្ងឺ កូវីដ ១៩។

ដើម្បីទប់ស្កាត់ការរាតត្បាតនៃជម្ងឺកូវីដ ១៩ រដ្ឋាភិបាលកម្ពុជាបានរិតត្បិតការធ្វើដំណើរតាំងពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០២១ ប៉ុន្តែបានបន្ធូរបន្ថយការរឹតត្បឹតចាប់ពីចុងខែមេសា។ ប្រជាពលរដ្ឋត្រូវបានណែនាំមិនឱ្យធ្វើដំណើរប្រសិនបើមិនចាំបាច់។ អាជីវកម្មដែលមិនសំខាន់ក្នុងតំបន់បិតខ្ទប់ មិនត្រូវបានអនុញ្ញាតឱ្យដំណើរការ។ ដូចនេះ អាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងកំឡុងពាក់កណ្តាលខែមេសា ឆ្នាំ២០២១។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។ ប៉ុន្តែតម្លៃដឹកជញ្ជូនបានកើនឡើង ក្នុងកំឡុងការរាតត្បាតនៃមេរោគ កូវិត ១៩។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ ប្រៀបធៀបរយៈពេលនេះជាមួយនឹងឆ្នាំ ២០២០ ត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

មិនមានផលប៉ះពាល់ចំបងណាមួយដែលបណ្តាលមកពីការប្រែប្រួលនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលឡើយ ក្រៅពីគោលនយោបាយដែលពាក់ព័ន្ធនឹងវីរុសកូវីដ-១៩ ដែលរួមមានការកាត់បន្ថយចំណាយរដ្ឋ និងការរឹតត្បឹតលើវិស័យមួយចំនួនដល់សេដ្ឋកិច្ចជាតិ ដូចជាវិស័យទេសចរណ៍។

## ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖

ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១

បានឯកភាព និង អនុម័ត

ឈ្មោះ Kevin Whitcraft

តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល

បានឯកភាព និង អនុម័ត

ឈ្មោះ ងន សាំង

តួនាទី៖ នាយកប្រតិបត្តិ

